រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងកម្ពុជា-វៀតណាម (១៩៧៩-២០០៨)

## Cambodia-Vietnam Relations (1979-2008)

កា ម៉ាធុល

និក្ខេបបទបណ្ឌិត វិទ្យាសាស្ត្រនយោបាយ

ឯកទេសៈ វិទ្យាសាស្ត្រនយោបាយ

២០១១

Scanned by CamScanner

រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងកម្ពុជា-វៀតណាម(១៩៧៩-២០០៨)

## Cambodia-Vietnam Relations ( 1979-2008 )

ភា ម៉ាធុល

និក្ខេបបទបណ្ឌិត វិទ្យាសាស្ត្រនយោបាយ
ឯកទេសៈ វិទ្យាសាស្ត្រនយោបាយ

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត សុខ ទូច

ឆ្នាំ ២០១១

Scanned by CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ ៧៣៤/១១ របសក

# សេចក្ដីសម្រេច
## ស្ដីពី
## ការអនុញ្ញាតឱ្យបេក្ខជនបណ្ឌិតការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

## ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣/០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួល បទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩។
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា។
- យោងចំណារឯកភាពរបស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ លើលិខិតស្នើសុំរបស់រាជបណ្ឌិត្យសភាកម្ពុជា ស្ដីពីគម្រោងបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត វគ្គទី១។
- យោងគោលការណ៍ស្ដីពីលក្ខខណ្ឌជ្រើសរើស និងបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត នៅរាជបណ្ឌិត្យសភាកម្ពុជា ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

## សម្រេច

**ប្រការ ១៖** អនុញ្ញាតឱ្យបេក្ខជន **ភា ម៉ាឌុល** បេក្ខជនបណ្ឌិត វគ្គទី១ ឯកទេស **វិទ្យាសាស្ត្រនយោបាយ** នៃរាជបណ្ឌិត្យសភាកម្ពុជា ការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

**ប្រការ ២៖** គណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បណ្ឌិត ផ្នែកបណ្ដុះបណ្ដាល និង ស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា និង សាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១១
**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខួត ធីតា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180 Website: www.rac-academy.edu.kh, E-mail: info@rac-academy.edu.kh, P.O Box 531 Phnom Penh, Cambodia

Scanned by CamScanner

## មាតិកា


ឧទ្ទិសស្នាដៃ......................................................................................v
សេចក្តីថ្លែងអំណរគុណ ..............................................................................vi
អំណះអំណាង..........................................................................................vii
ពាក្យប្រើជាអក្សរកាត់...............................................................................viii
មូលន័យសង្ខេប ......................................................................................x
Absract ..................................................................................................xii
សង្ខេបនិក្ខេបបទ.....................................................................................xii
Summarize............................................................................................xxxiii
អារម្ភកថា .............................................................................................lvi


## សេចក្តីផ្តើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ.................................................................... ១
២. ចំណោទបញ្ហានៃនិក្ខេបបទ ...................................................................... ១
៣. គោលបំណងនៃកាស្រាវជ្រាវ....................................................................២
៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ .............................................................៣
៥. វិធីសាស្ត្រស្រាវជ្រាវ ...............................................................................៣
៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ...............................................................៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................................... ៤


## ជំពូក១
## ប្រវត្តិទំនាក់ទំនងកម្ពុជា-វៀតណាម


**១. ទិដ្ឋភាពប្រវត្តិនយោបាយឥណ្ឌូចិន**................................................................ ៦
១.១. ទិដ្ឋភាពប្រវត្តិនយោបាយប្រទេសកម្ពុជា................................................. ៩
១.២. ទិដ្ឋភាពប្រវត្តិនយោបាយប្រទេសវៀតណាម...........................................២២
**២. ការរីកសាយអាណានិគម** ........................................................................ ២៤
២.១. បុព្វបទនៃទំនាក់ទំនងកម្ពុជា-វៀតណាម ........................................... ២៥
២.២. គំនិតបង្កើតបក្សកុំម្មុយនីស្តឥណ្ឌូចិន ................................................២៦
**៣. ចលនាប្រឆាំងនឹងអាណានិគម** ................................................................. ៣២
៣.១. ភាពខ្លាំងរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ...........................................៤២
៣.២. ភាពខ្សោយរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន .........................................៤៣
៣.៣. ការបែកបាក់បក្សកុម្មុយនីស្តឥណ្ឌូចិន ............................................. ៤៦




Scanned by CamScanner

## ជំពូក២
## ឥទ្ធិពលវៀតណាមមកលើកម្ពុជា


**១. នយោបាយវៀតណាមចំពោះក្រុមខ្មែរក្រហម** ..................... ៥១
១.១. ទំនាក់ទំនងអ្នកកុម្មុយនិស្តខ្មែរនិងវៀតណាម ..................... ៥៩
១.២. នយោបាយវៀតណាមចំពោះរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ..................... ៦១
១.៣. ផែនការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ..................... ៦៦
**២. ឥទ្ធិពលវៀតណាមនៅកម្ពុជា** ..................... ៧៥
២.១. តួនាទីវត្តមានកងទ័ពវៀតណាម ..................... ៧៦
២.២. កំណែនកងទ័ព ..................... ៨៤
២.៣. កំណែនក៥ ..................... ៨៧
២.៤. អត្ថន័យនយោបាយនៃថ្ងៃ៧មករា ..................... ៩១
**៣. ការពង្រឹងសម្ព័ន្ធភាពនៃប្រទេសទាំងពីរ** ..................... ៩៥
៣.១. សម្ព័ន្ធភាពឥណ្ឌូចិន ..................... ៩៥
៣.២. សម្ព័ន្ធភាពរដ្ឋនិងរដ្ឋ ..................... ៩៦
៣.៣. សម្ព័ន្ធភាពខេត្តនិងខេត្ត ..................... ៩៨
**៤. ឥទ្ធិពលកម្ពុជានៅលើឆាកអន្តរជាតិ** ..................... ៩៩


## ជំពូក៣
## នយោបាយវៀតណាមចំពោះវិបត្តិកម្ពុជា


**១. ការវិវត្តិនយោបាយអន្តរជាតិ** ..................... ១០៩
១.១. កម្មវិធីប៉េរ៉េស្ត្រូយកា ..................... ១១០
១.២. កម្មវិធីដូយម៉ើយ ..................... ១១១
**២. ជំហរនយោបាយវៀតណាមចំពោះរដ្ឋាភិបាលក្រុងភ្នំពេញ** ..................... ១១២
២.១. នយោបាយវៀតណាមក្នុងជម្លោះកម្ពុជា ..................... ១១៥
២.២. ជំហរនយោបាយប្រទេសនៅឥណ្ឌូចិន ..................... ១១៨
២.៣. ទស្សនៈវៀតណាមចំពោះអាស៊ាន ..................... ១២១
**៣. សន្និសិទអន្តរជាតិស្តីពីបញ្ហាកម្ពុជា** ..................... ១២៣
៣.១. នយោបាយវៀតណាម ..................... ១២៥




Scanned by CamScanner

៣.២. បញ្ហាអាសនៈកម្ពុជា ........ ១២៨

**៤. ជំហរនយោបាយប្រទេសមហាអំណាច** ........ ១៣៦

៤.១. ជំហរនយោបាយសហរដ្ឋអាមេរិក ........ ១៣៦

៤.២. នយោបាយសហភាពសូវៀត ........ ១៤៥

៤.៣. ជំហររដ្ឋាភិបាលចិន ........ ១៥០

**៥. ការដកកងទ័ពវៀតណាម** ........ ១៥៥

៥.១. ជំហរនយោបាយរដ្ឋាភិបាលក្រុងភ្នំពេញ ........ ១៥៨

៥.២. ជំហរនយោបាយរបស់រដ្ឋាភិបាលចម្រុះ. ........ ១៥៩

៥.៣. ជំហរនយោបាយរដ្ឋាភិបាលក្រុងហាណូយ ........ ១៦៦

៥.៤. ទស្សនៈនយោបាយអាស៊ាន ........ ១៦៧

**៦. ដំណោះស្រាយវិបត្តិនយោបាយកម្ពុជា** ........ ១៧៣

៦.១. ជំហររដ្ឋាភិបាលក្រុងភ្នំពេញ ........ ១៧៣

៦.២. ការវិវត្តនៃនយោបាយកម្ពុជា ........ ១៧៦

៦.៣. ជំនួបនយោបាយ សីហនុ-ហ៊ុនសែន ........ ១៨១

## ជំពូក៤
## កិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម

**១. កិច្ចសហប្រតិបត្តិការលើផ្នែកស្មារតី** ........ ១៨៧

១.១. ការបញ្ចូលភាសាវៀតណាមក្នុងកម្មវិធីសិក្សា ........ ១៨៧

១.២. សហប្រតិបត្តិការអប់រំនិងវប្បធម៌ ........ ១៨៩

១.៣. ផ្នែកវប្បធម៌ ........ ១៩២

**២. សេដ្ឋកិច្ចទ្វេភាគីកម្ពុជា-វៀតណាម** ........ ១៩៦

២.១. សេដ្ឋកិច្ចទ្វេភាគីនៃប្រទេសទាំងពីរ ........ ១៩៦

២.២. ជំនួយវៀតណាម ........ ១៩៨

២.៣. ជំនួយសម្ភារៈយោធា ........ ២០០

**៣. លំហូរពាណិជ្ជកម្មរបស់ប្រទេសទាំងពីរ** ........ ២០៤

៣.១. លំហូរពាណិជ្ជកម្មរបស់វៀតណាមមកកម្ពុជា ........ ២០៤

៣.២. នយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តជាប់ព្រំដែន ........ ២០៤

៣.៣. កិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ ........ ២១០

៣.៤. ភាពមិនប្រក្រតីនានាកើតមាននៅតាមព្រំដែន ........ ២១៣



Scanned by CamScanner

## ជំពូកទី៥

## ការប្រឈម ក្ដីសង្ឃឹម


**១. ចិត្តសាស្ត្រសង្គម** ....... ២១៨

១.១. ចរិតជនជាតិខ្មែរចំពោះវៀតណាម ....... ២១៨

១.២. ការសំលឹងមើលរបស់វៀតណាមមកកម្ពុជា ....... ២១៩

**២. ការប្រឈមនានាកើតមាននៅកម្ពុជា** ....... ២២៣

២.១. បញ្ហាអនិកជនវៀតណាមនៅកម្ពុជា ....... ២២៣

២.២. ភាពធូរលុងរបស់មន្ត្រីការពារច្រកព្រំដែន ....... ២៤០

២.៣. នយោបាយវៀតណាមចំពោះជនជាតិខ្មែរដើមនៅវៀតណាម ....... ២៤២

២.៤. ការរិតបន្តឹងសិទ្ធិសេរីភាព ....... ២៤៤

២.៥. ការរើសអើងជាតិសាសន៍ ....... ២៥៣

២.៥.១. កង្វះច្បាប់ការពារជនជាតិដើម ....... ២៥៣

២.៥.២. នយោបាយកម្ពុជាចំពោះខ្មែរកម្ពុជាក្រោម ....... ២៥៤

**៣. ការប្រឈមលើបញ្ហាព្រំដែន** ....... ២៥៥

៣.១. ទិដ្ឋភាពប្រវត្តិសាស្ត្រ ....... ២៥៥

៣.១.១. ភូមិសាស្ត្រ ....... ២៥៦

៣.១.២.បច្ចេកទេស ....... ២៥៦

៣.១.៣.ច្បាប់ព្រំដែន ....... ២៥៩

៣.១.៤. គំនិតនយោបាយ ....... ២៥៩

៣.១.៥. អត្ថន័យព្រំដែន ....... ២៦០

៣.១.៦. អត្ថន័យនយោបាយ ....... ២៦០

៣.២. ព្រំដែនកម្ពុជា-វៀតណាម ....... ២៦១

៣.២.១. ការប្រើប្រាស់ផែនទីព្រំដែនរបស់ភាគីកម្ពុជា ....... ២៦៥

៣.២.២. ក្រុមភូមិសាស្ត្រឥណ្ឌូចិន ....... ២៦៥

៣.៣. វិបត្តិព្រំដែនកម្ពុជា-វៀតណាម ....... ២៧១

៣.៣.១. ផលវិបាក ....... ២៧៣

៣.៤. ដំណោះស្រាយវិបត្តិព្រំដែន ....... ២៧៩

៣.៤.១. ដំណោះស្រាយក្នុងក្របខ័ណ្ឌទ្វេភាគី ....... ២៩៣

៣.៤.២. ដំណោះស្រាយក្នុងក្របខ័ណ្ឌអន្តរជាតិ ....... ២៩៤

**សេចក្ដីសន្និដ្ឋានរួម** ....... ២៩៦

**ឧបសម្ព័ន្ធ** ....... ២៩៩

**ឯកសារគន្ថនិទ្ទេស** ....... ៣៣៥




Scanned by CamScanner

# មូលន័យសង្ខេប

កិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម នៅលើវិស័យសេដ្ឋកិច្ច ដើម្បីជួយគ្នាកសាងប្រយោជន៍ជាតិឱ្យខ្លាំងពូកែ កសាងជីវភាពសប្បុរសប្បាយ និងមានសុភមង្គល ភាគីទាំងពីរ បង្កើតការទាក់ទងនិងកិច្ចសហប្រតិបត្តិការ ប្រកបដោយភាតរៈភាព ដែលមានផលប្រយោជន៍ទាំងសងខាង និងជួយឧបត្ថម្ភគ្នាលើគ្រប់វិស័យសេដ្ឋកិច្ច វប្បធម៌ អប់រំវិជ្ជាពេទ្យ និងវិទ្យាសាស្ត្រ បច្ចេកទេស និងការផ្លាស់ប្តូរអ្នកបច្ចេកទេស ផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមក ខាងការកសាងជាតិឱ្យមានការរីកចម្រើន។

ជាការអនុវត្ត វៀតណាម បានចុះកិច្ចព្រមព្រៀងធ្វើពាណិជ្ជកម្មជាមួយកម្ពុជា ដោយធ្វើការដូរដោះទំនិញគ្នាទៅវិញទៅមក រវាងខេត្តដែលមានព្រំដែនជាប់គ្នា។ រដ្ឋាភិបាលទាំងពីរ បានបើកឱ្យមានដំណើរការឡើងវិញនូវជើងហោះហើរពីហាណូយ-ភ្នំពេញ និង ពីភ្នំពេញទៅហាណូយ សម្រាប់យន្តហោះដឹកទំនិញនិងដឹកអ្នកដំណើរ។ មិនតែប៉ុណ្ណោះ វៀតណាមបានជួយលើកដាក់ទំនិញឆ្លងដែនកម្ពុជា និងអនុញ្ញាតឱ្យកម្ពុជា ប្រើប្រាស់កំពង់ផែព្រៃនគរសំរាប់ផ្ទេរ ស្តុកទំនិញ និងជួយមធ្យោបាយដឹកជញ្ជូនទំនិញកម្ពុជា ពីកំពង់ផែព្រៃនគរមកភ្នំពេញ និងពីភ្នំពេញ នៅប្រទេសផ្សេង ដែលឆ្លងកាត់ប្រទេសវៀតណាម។ សកម្មភាពនេះ បានជួយសំរាលការលំបាក់របស់កម្ពុជា បានមួយកំរិតធំក្នុងពេលដែលមធ្យោបាយដឹកជញ្ជូនកម្ពុជា ជួយនឹងការខ្វះខាត។

នៅលើវិស័យវប្បធម៌ ភាគីទាំងពីរ បានរៀបចំសកម្មភាពវប្បធម៌ និង សិល្បៈជាច្រើនដូចជាការផ្លាស់ប្តូរប្រតិបត្តិករសិល្បៈករ កីឡាករ អ្នកសារព័ត៌មាន រៀបចំសប្តាហ៍វប្បធម៌វៀតណាម-កម្ពុជា រៀបចំពិធីសមោលសរសិល្បៈយុវជននៃប្រទេសទាំងពីរ។ សកម្មភាពទាំងអស់នេះ បានរួមចំណែកបង្កឱ្យមានភាពស្និទ្ធស្នាល និងយល់គ្នាទៅវិញទៅមក រវាងបណ្តាស្រទាប់ប្រជាជននៃប្រទេសទាំងពីរ ពិសេសគឺ បានរួមចំណែកដល់ការឃោសនាអប់រំដល់ស្រទាប់យុវវ័យ អំពីចំណងទាក់ទងមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរ។ ក្រុមសិល្បៈនៃស.ស.វ. បានមកសំដែងនៅស.ប.ក. ក្នុងន័យពង្រឹងចំណងសាមគ្គីភាពកម្ពុជា-វៀតណាម ឱ្យកាន់តែរឹងមាំថែមទៀតក្នុងខែមិត្តភាពឆ្នាំ១៩៧៩។ នៅក្នុងឱកាសនោះលោក ស៊ី ដារី បានបញ្ជាក់ថា "ប្រជាជនយើងទាំងពីរមានវប្បធម៌ដូចគ្នា ម្លោះហើយសិល្បៈនិងវប្បធម៌របស់យើងមានលំនាំប្រហាក់ប្រហែលគ្នា ប្រជាជនយើងទាំងពីរកម្ពុជា-វៀតណាម ផ្លាស់ប្តូរគ្នាទៅវិញទៅមកក្នុងវិស័យនេះ។ ប្រជាជាតិទាំងពីរបានខិតកាន់តែជិតគ្នា នូវមនោសញ្ចេតនា ជាភាតរៈផ្សារភ្ជាប់ជាតិកាន់តែរឹងប៉ឹងឡើង ពុំអាចមានសត្រូវណាមកកាត់ផ្តាច់បានឡើយ"។

ក្នុងការធ្វើទំនាក់ទំនងអន្តរជាតិ ជាមួយប្រទេសវៀតណាម អត្ថន័យក្នុងវិស័យសិល្បៈសុទ្ធសឹងបង្កប់ន័យ ដែលចង់បង្ហាញពីចំណងសាមគ្គីភាពកម្ពុជានិងវៀតណាម ក្នុងការតស៊ូរំដោះជាតិមាតុភូមិពីបរទេសឈ្លានពាន។ ចម្រៀង ដែលពេញនិយមជាងគេគឺចំរៀងដែលបង្ហាញពីសកម្មភាពរបស់លោក ហូ ជីមិញ និង ចម្រៀងដែលសំដែងពីចំណងសាមគ្គីភាពកម្ពុជា-វៀតណាម។ ចម្រៀងរបៀបនេះ បានត្រូវបញ្ចូលក្នុងកម្មវិធីសិក្សាបឋមសិក្សា កុមារកម្ពុជាតូចៗចេះរៀងចម្រៀងបែបនេះស្ទើរគ្រប់ៗគ្នា។

ក្នុងទិដ្ឋភាព នៃចំណងទំនាក់ទំនងសហប្រតិបត្តិការលើគ្រប់វិស័យរវាងវៀតណាម និងកម្ពុជា ដែលពីមួយថ្ងៃទៅមួយ ថ្ងៃកាន់តែត្រូវបានពង្រឹងនិងពង្រីកទំនាក់ទំនងជាប្រពៃណី មិត្តភាពសហប្រតិបត្តិការ និងជួយទំនុកបម្រុងគ្នាទៅវិញទៅមក រវាងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ នេះជា



Scanned by CamScanner

កត្តាគន្លឹះមួយហើយក៏ជាប្រទីបបំភ្លឺក្នុងការរឹតចំណងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ និងប្រជាជាតិនៃយើងទាំងពីរ។ លទ្ធផលកិច្ចសហប្រតិបត្តិការ ដែលសម្រេចរវាងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ក្នុងរយៈពេលកន្លងមកបានរួមចំណែកយ៉ាងសកម្មទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់បណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ព្រមទាំងរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមនៅក្នុងតំបន់នៃប្រទេសយើងទាំងពី។



Scanned by CamScanner

Abstract

The Cooperation between Cambodia-Vietnam on the economic sector for helping each other to restore the nations, the standard of living and happiness strongly, two parties establish relation and cooperation with fraternal that have the benefit each other and supporting on the economic culture vocational medicine, technicality and changing the technician experience each other and restoration of nation for development.

With implementation, Vietnam has agreement on the commerce with Cambodia and change goods each other between the province that attachment border, Two governments has process the flight from Hanoi and Phnom Penh or and Phnom Penh and Hanoi for passengers and goods, not only Vietnam has loaded the goods transit for border of Cambodia and allowed Cambodia to use the port of Saigon for transferring, stock goods and help to transport Cambodia goods from Saigon port to Phnom Penh and from Phnom Penh to other countries that transit Vietnam. These activities have relaxes the difficulties of Cambodia while Cambodia lacks the means. On the culture sector, two parties manage the active culture and art a lot such as changing the delegation of artist, footballer and rises and prepare the weekly culture Vietnam and Cambodia and manage night-dancing club of Youth of two counties these activities to take part in the sympathy and understanding each other between two nations, especially, to take port on to promote the educational youth level on friendship and tradition between two countries the team art of the socialist of Vietnam to express in the people's republic of Cambodia in the meaning strengthening solidarity between Vietnam and Cambodia in 1979. In the occasion, Mr. SI Dary expressed that our both people has culture the same, so art and culture bring similarity, our both people Vietnam and Cambodia has changed each other in this sector, the reconciliation the two nations strongly, and has no enemy to separate yet.

In the relation of international with Vietnam in that sector to hide meaning deeply that express the solidarity Vietnam and Cambodia in the liberation the country from invading foreigner the song that has popularity more than the other is the expressive the active, Ho Chi Minh and the song that express from the solidarity of Vietnam and Cambodia, such song put into the program study of primary school, the kids can sing this song almost.

In the aspect of solidarity and cooperation on all sectors between Vietnam and Cambodia from day to day has strengthening as tradition and friendship without dispute, though closing page history of the dispute between China and Vietnam toward the end of page history before they not look in point's face and de came cruel enemy, but now, two countries has become a friend and competitive partner on economic sector.



Scanned by CamScanner

## សង្ខេបនិក្ខេបបទ

វិទ្យាសាស្ត្រនយោបាយគឺ ពិតជាការកសាងជាអចិន្ត្រៃនូវតម្លៃមនុស្សជាតិ ដែលកំពុង មានជីវិតរស់ នៅលើកពផែនដី ហើយប្រទេសជាតិនីមួយៗ បានខិតខំពង្រឹងឥស្សរភាពក្នុងឋានៈជារដ្ឋប្រកបដោយស្វ័យភាព និងឧត្តមភាពខាងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយវាសនានៃប្រទេសនីមួយៗពុំអាចកាត់ ផ្តាច់ចេញពីទំនាក់ទំនងរួមជាទូទៅទាំងក្នុងតំបន់ ក៏ដូចជាទាំងក្នុងពិភពលោកទាំងមូលដែរ ដែលប្រមូលផ្តុំទៅដោយប្រទេស ជាតិសាសន៍ជាច្រើនដែលមានភាសា និងវប្បធម៌ខុសៗគ្នា។ ទាំងនេះជាការពិតនៃប្រវត្តិសាស្ត្រមួយ ដែលអតីតកាល និងបច្ចុប្បន្នកាល បានបង្ហាញឱ្យឃើញរួចមកហើយថាគ្មានប្រទេសណាមួយ ដែលផ្តាច់ខ្លួនទៅរស់នៅឯកកោតែឯកឯងចេញពីចក្រវាឡនេះបានឡើយ។

យ៉ាងណាមិញ ប្រទេសកម្ពុជា ក៏មិនអាចកាត់ផ្តាច់ចេញពីការវិវត្តទូទៅនៃ នយោបាយក្នុងឥណ្ឌូចិន និងអាស៊ីអាគ្នេយ៍បានដែរ។ ចំណែកឯអនាគតនៃឥណ្ឌូចិន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ក៏ត្រូវមានទំនាក់ទំនងទៅនឹងការវិវត្តនៃនយោបាយរបស់ប្រទេសកម្ពុជាផងដែរ។ ទន្ទឹមនឹងនេះ ស្ថានភាពភូមិ សាស្ត្រនៃប្រទេស ដែលនៅជិតខាងគ្នា តែងតែទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក។ ជាទូទៅកាលណាប្រទេសជិតខាងមួយ មានអំណាចខាងនយោបាយ និងយោធាខ្លាំង ឬសេដ្ឋកិច្ចខ្ពស់ តែងតែមានឥទ្ធិពល ទៅលើប្រទេសជិតខាង ដែលអន់ថយជាងខ្លួន។

ក្នុងន័យនេះ កម្ពុជាត្រូវមានឆន្ទៈយ៉ាងមាំហើយប្តេជ្ញាថា មិនឱ្យការភ្ញាក់រឭករបស់ខ្លួនក្លាយទៅជា ភាពស្រឡាំងកាំង ស្លន់ស្លោរនិងអស់សង្ឃឹមឡើយ ហើយត្រូវសិក្សាឱ្យបានច្បាស់លើវិស័យនយោបាយ នយោបាយការបរទេស និងប្រវត្តិសាស្ត្ររបស់ប្រទេសទាំងអស់ នៅជិតខាងខ្លួនឱ្យបានច្បាស់។ ហើយត្រូវមានទ្រឹស្តីនយោបាយជាមូលដ្ឋានជាតិមួយប្រាកដ និយម ដែលអនុញ្ញាតឱ្យខ្មែរមានកម្លាំងក្នុងគ្រប់មជ្ឈដ្ឋានក្នុងគ្រប់វិស័យ ដើម្បីកសាងប្រទេសជាតិឱ្យបានចំរុងចំរើនរុងរឿង។ បើស្រុកខ្មែរបានរុងរឿងខ្លាំងពូកែ មានកិត្យានុភាព រន្ទឺទៅគ្រប់ទិសទី មិនមែនដោយសារទេព្រះមហាក្សត្រមួយព្រះអង្គនោះទេ។

ដោយសារអ្នកប្រាជ្ញ អ្នកចេះដឹង នាម៉ឺនមន្ត្រី និងប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលបាននាំគ្នារករូបមន្តទ្រឹស្តី នយោបាយប្រាកដនិយមរបស់ខ្លួនឃើញ ដើម្បីកសាងជាតិមាតុភូមិ។ ហើត្រូវប្រកាន់នូវស្មារតីភ្ញាក់រលឹកនិងជឿជាក់ថា ប្រទេសនីមួយៗពុំអាចរស់នៅក្នុងភាពឯកកោម្នាក់ឯងបានឡើយ។ ការធ្វើទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ពិតជាកញ្ចក់មួយដ៏ភ្លឺថ្លា ឆ្លុះឱ្យឃើញនូវគុណសម្បត្តិ និងគុណវិបត្តិ ដែលកើតមានឡើងពីការធ្វើទំនាក់ទំនងនេះ។

ប្រវត្តិទំនាក់ទំនងរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម ជាប្រវត្តិសាស្ត្រមួយពោរពេញទៅដោយភាពគ្រោតគ្រាតចម្បាំងស៊ីសាច់ហុតឈាមរវាងប្រជាជាតិទាំងពីរ តែងតែកើតមានឡើងឥតឈប់ឈរនៅអតីតកាល។ ជាលទ្ធផលនៃជម្លោះ ប្រទេសកម្ពុជាទទួលបរាជ័យជារៀងរហូត ដោយសារការចាញ់ប្រៀបខាងនយោបាយ យោធា និង មនោគមវិជ្ជារបស់វៀតណាម។

នៅពាក់កណ្តាលសតវត្សរ៍ទី១៩ ប្រទេសកម្ពុជាត្រូវបានប្រទេសធំពីរ វៀតណាម និងសៀមមានមហិច្ឆិតាចង់ពុះប្រទេសនេះជាពីរចំណែកហែកចែកគ្នា ដោយយកទន្លេមេគង្គធ្វើជាព្រំប្រទល់រវាងវៀតណាមនិងសៀម។ ដោយធ្វើការបែងចែកទឹកដីចាប់ពីត្រើយខាងលិចទន្លេមេគង្គ ជាកម្មសិទ្ធិរបស់សៀម រីឯទឹកដីនៅភាគខាងកើតទន្លេមេគង្គ ជារបស់វៀតណាម។ ជនជាតិសៀមមើលមកជនជាតិ



Scanned by CamScanner

កម្ពុជាថាជា " កូន " ដែលត្រូវផ្តល់លាភទ្រព្យ ជាស្បៀងសារអាករ និងផ្តល់មនុស្សមកឱ្យសៀម ដែលជាឪពុកយកទៅធ្វើសង្គ្រាម។ រីឯជនជាតិវៀតណាម តែងចាត់ទុកខ្លួនជាសត្វខ្លា ដែលគេចង់ក្រញែកនៅពេលណាក៏បាននៅ ពេលដែលកម្ពុជាធ្វើឲ្យគេខឹង។ ជនជាតិវៀតណាមសម្លឹងមើលមកជនជាតិកម្ពុជា ថាជាមនុស្សល្ងង់ខ្លៅ ដែលគេមានភារកិច្ចត្រូវចូលមកជួយអប់រំឱ្យចេះស្គាល់អរិយធម៌ និងមើលមកប្រទេសកម្ពុជា ថាជាកន្លែងសម្រាប់គេបង្ហូរជនជាតិគេចូលមករស់នៅ។

នៅឆ្នាំ១៨១៣ អធិរាជវៀតណាម ផ្តល់អំណាចឱ្យទេសាភិបាលក្រុងព្រៃនគរ ត្រួតត្រាកម្ពុជាទាំងមូល។ ទេសាភិបាលក្រុងព្រៃនគររូបនោះ បានកេណ្ឌប្រជាជនខ្មែរឱ្យជីកប្រឡាយចេញពីដៃខាងលិចទន្លេមេគង្គទៅភ្ជាប់ច្រកនៃឈូងសមុទ្រសៀម ដែលហៅថា ប្រឡាយវិញតេ (Vinh Te Canal) ប្រឡាយនេះមានចម្ងាយ៥៣គីឡូម៉ែត្រ។ ប្រឡាយវិញតេ ចំណាយពេល៥ឆ្នាំ ហើយក៏ជាការចំណាយជីវិតខ្មែរអស់ច្រើននាក់ ដែលវៀតណាមកេណ្ឌប្រជាពលរដ្ឋខ្មែរទាំងបង្ខំឱ្យទៅស្លាប់នៅក្នុងគ្រានោះ។

នៅក្រោមអំណាចគ្រប់គ្រងរបស់អធិរាជវៀតណាមឈ្មោះ មិញ ម៉ាង ស្តេចនិងអ្នករាជការខ្មែរត្រូវបានវៀតណាមតម្រូវឲ្យពាក់អាវផាយ និងបួងសក់ដូចវៀតណាមដែរ។ ក្នុងការគ្រប់គ្រងប្រទេសកម្ពុជា អធិរាជវៀតណាម មិញ ម៉ាង បានធ្វើអំពើសាហាវបំផុតលើប្រជាជនកម្ពុជា ពេលនោះហើយដែលកើត មានបញ្ហាកម្តប់តែអុងកើតមានឡើង។ ដើម្បីរំលឹកពីអំពើឃោរឃៅរបស់វៀតណាម បានធ្វើមកលើប្រជាជនកម្ពុជា។ ក្នុងចន្លោះឆ្នាំ១៨៤១ ដល់ឆ្នាំ១៨៤៥ ប្រទេសកម្ពុជា ត្រូវបានវៀតណាមកាត់យកទាំងអស់ ហើយត្រូវបានឧត្តមសេនីយ៍ វៀតណាមម្នាក់គឺលោក ទ្រឿង មិញយ៉ាង ត្រួតត្រាក្នុងនាមជាអធិរាជវៀតណាម។ ពេលនោះអស់មានពាក្យថា កម្ពុជាក្នុងឋានៈជាប្រទេសទៀតហើយ។ ដោយសារតែដែនដីមួយផ្នែករបស់ប្រទេសកម្ពុជា ត្រូវសៀមកាត់យកនិងមួយផ្នែកទៀតវៀតណាមកាត់យក។

ការណ៍ដែលកម្ពុជា អាចនៅមានជីវិតនោះ បង្ហាញឱ្យឃើញនូវភាពពុំបាច់ស្រាច់របស់មេដឹកនាំសៀមនិងយួន ក្នុងការជំរុញការប្រកួតប្រជែងរបស់គេឱ្យដល់ទីបញ្ចប់។ នៅពេលមានការប្រយុទ្ធគ្នាជាច្រើនលើក ក្នុងរយៈពេលយ៉ាងយូរនៅលើទឹកដីកម្ពុជា ពួកសៀមនិងយួន បានអនុញ្ញាតឱ្យកម្ពុជានៅរស់រានមានជីវិត សម្រាប់ធ្វើជាភូមិភាគចន្លោះកណ្តាលប្រទេសទ្រនាប់ រវាងប្រទេសទាំងពីរនិងជារដ្ឋចំណុះរបស់ពួកគេ ព្រោះថាកម្ពុជា ក្នុងលក្ខណៈបែបនេះ អាចផ្តល់ផលប្រយោជន៍យ៉ាងច្រើនសម្រាប់ពួកគេទៅថ្ងៃក្រោយៗបន្តទៀត។

ប៉ុន្តែទោះបីក្នុងសភាពការណ៍យ៉ាងនេះក៏ដោយ ក៏ចលនាតស៊ូរបស់អ្នកជាតិនិយមខ្មែរមិនរួញទេ។ មនុស្សរយៃកណ្តាលរត់ចូលព្រៃ ដើម្បីគេចមិនបង់ពន្ធជាស្រូវអង្ករឱ្យវៀតណាម ហើយមិនឱ្យវៀតណាមចាប់ធ្វើទាហាន។ នីតិវិធីគ្រប់គ្រងប្រទេសកម្ពុជា សៀមនិងវៀតណាម បានប្តូរពីជម្លោះមកត្រូវគ្នាតាមមធ្យោបាយការទូត ហើយធ្វើជាស្រុះស្រួលគ្នា ដើម្បីរួមគ្នាកាន់កាប់ប្រទេសកម្ពុជា។

ព្រះបាទ អង្គឌួង យល់ពីបញ្ហានេះ បានប្តូរមករកជំនួយពីជនជាអឺរ៉ុបវិញម្តង ដោយឃើញថាពួកគេមានអាវុធទំនើបៗ ហើយអាចគាំពារកម្ពុជា ឱ្យរួចផុតពីការលេបត្របាក់កម្ពុជា ពីសៀមនិងយួន។ សម្ព័ន្ធមេត្រីភាព ព្រះបាទអង្គឌួង និងលោក ហ្សង់ ក្លូតមីស បានកើតឡើងក្នុងខណៈលោក ហ្សង់ ក្លូតមីស ជាសង្ឃរាជកាតូលិចបារាំងមួយអង្គ។ លោក បានឆ្លើយនឹងសំណួមពរដ៏ត្រឹមត្រូវ របស់ព្រះបាទអង្គឌួង ថា "បារាំងអាចជួយឱ្យកម្ពុជារើខ្លួនរួចពីសៀមផង និងការពារមិនឱ្យវៀតណាមចូលមកបាន



Scanned by CamScanner

ផង"។ ការសម្រេចចិត្តរបស់បារាំង ក្នុងការការពារប្រទេសកម្ពុជា ឱ្យជៀសផុតពីការជ្រៀតជ្រែករបស់សៀមនិងយួន ចាប់ផ្តើមពីទសវត្សរ៍ឆ្នាំ១៨៦០ អាចចាត់ទុកថា ជាការធានាផ្លូវនេះឱ្យនៅមានអត្ថិភាព។ លើសពីនេះទៀតបារាំង មិនត្រឹមតែរក្សាបាននូវវត្តមានរដ្ឋនេះប៉ុណ្ណោះទេ បារាំងក៏បានផ្តល់ជាការគាំទ្រដល់ការលើកស្ទួយនូវកិត្យានុភាពរបស់ព្រះរាជវង្ស និង មន្ត្រីព្រះបរមរាជវាំង ដោយការគោរពរាប់អានព្រះរាជាខ្មែរ ព្រះបាទនរោត្តម ក្នុងរបៀបមួយដែលអាចឱ្យទ្រង់រក្សាតួនាទីជាអ្នកដឹកនាំជានិមិត្តរូបជាតិ។ នៅឆ្នាំ១៨៦៣ ព្រះបាទនរោត្តម យល់ព្រមតាមកិច្ចព្រមព្រៀងមួយ ជាមួយបារាំងធានាការពារទឹកដីរបស់ខ្មែរ ដែលនៅសេសសល់ពីការឈ្លានពានរបស់ប្រទេសជិតខាងទាំងពីរគឺសៀមនិងយួន ។

ដើម្បីទប់ស្កាត់ការរាទីនិយមរបស់ប្រទេសទាំងពីរនេះ ព្រះបាទអង្គឌួង បានពង្រឹងចំណងទំនាក់ទំនងជាមួយបារាំងកាត់តែខ្ពស់បន្ថែមមួយកម្រិតទៀត ដើម្បីយកបារាំងធ្វើជាខ្នងបង្អែកសម្រាប់រារាំងដល់ ការទាមទារខេត្តរបស់ខ្មែរ ពីសំណាក់ប្រទេសសៀមនិងយួន ដោយពឹងឱ្យបារាំងជួយការពារប្រទេសកម្ពុជា ឱ្យរួចផុតពីនយោបាយរាទីនិយមរបស់ប្រទេសជិតខាងទាំងពីរនេះ។

មុនពេលបារាំង ដាក់អាណានិគមនៅក្នុងប្រទេសកម្ពុជា កងទ័ពនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការវាយលុកចូលតំបន់កូសាំងស៊ីន តែត្រូវបរាជ័យ។ ដើម្បីបញ្ចប់សង្គ្រាមដណ្តើមគ្នាគ្រប់គ្រងដែនដីកូសាំងស៊ីន រវាងកម្ពុជានិងវៀតណាម បារាំងបានយកតំបន់កូសាំងស៊ីន ធ្វើជាទឹកដីអាណា-និគម ហើយដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជំនួសវិញ ហូតមកដល់ឆ្នាំ១៩៤៩ ក្រោយសង្គ្រាមលោកលើកទី ពីរបានបញ្ចប់ បារាំងបានធ្វើសេចក្តីសម្រេចចិត្តជាអត្តនោម័ត ដោយប្រគល់ទឹកដីកូសាំងស៊ីន ទៅឱ្យអំណាច បាវដាយ-វៀតណាម គ្រប់គ្រងជំនួសវិញ ដោយបានអះអាងថាប្រជាជនខ្មែររស់នៅតំបន់នោះមានចំនួនតិចជាងជនជាតិវៀតណាម (ប្រជាជនខ្មែរមានចំនួនប្រហែល ៦០០ ពាន់នាក់) មិនអាចគ្រប់គ្រង ទឹកដីមួយ ដែលមានជនជាតិវៀតណាមរស់នៅដ៏សន្ធឹកសន្ធាប់បានឡើយ។ ទង្វើរបស់បារាំង ក្នុងការកាត់ដីខ្មែរទៅឱ្យវៀតណាម បារាំងពុំបានធ្វើការពិភាក្សាជាមួយសម្តេចព្រះនរោត្តម សីហនុ ដែលជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ទង្វើរបៀបនេះបានធ្វើឱ្យជម្លោះរបស់កម្ពុជានិងវៀតណាម បានអូសបន្លាយ ហើយក្លាយជាការរើសអើងជាតិសាសន៍រវាងជនជាតិទាំងពីរ និងជាចំណុចរសើបនៃសង្គ្រាមចិត្តសាស្ត្រដែលស្ថិតនៅក្នុងស្មារតីជនជាតិកម្ពុជាសព្វថ្ងៃ។

ជាច្រើនសតវត្សរ៍មកហើយ ទំនាស់បញ្ហាទឹកដី បានធ្វើឱ្យមានសង្គ្រាមបង្ហូរឈាមគ្នាឥតឈប់ឈរ រវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ បរាជ័យរបស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅសតវត្សរ៍ទី១៩ គឺជាស្នាកស្នាមប្រវត្តិសាស្ត្រដ៏ជូរចត់ បន្សល់ទុកឱ្យប្រជាជនកម្ពុជាចងចាំមិនភ្លេច។ ប្រជាជនវៀតណាម បានបន្តការចូលជ្រៀតជ្រែកមករស់នៅលើទឹកដីនៃប្រទេសកម្ពុជា សឹងគ្រប់ទីកន្លែងមុននិងក្រោយសម័យអាណានិគមបារាំង។

នៅក្នុងប្រទេសកម្ពុជា ប្រជាជនវៀតណាម ប្រកបរបរអាជីវកម្មជាឈ្មួញ កម្មករចំការកៅស៊ូ និង អ្នកនេសាទជាដើម។ មិនត្រឹមតែប៉ុណ្ណោះ បារាំងបានជ្រើសរើសប្រជាជនវៀតណាម ជាច្រើនឱ្យធ្វើការក្នុងទេសាភិបាលអាណានិគមនិយម នៅក្នុងប្រទេសកម្ពុជា ដោយមិនអើពើពីទស្សនៈជាតិនិយមរបស់ប្រជាជនខ្មែរឡើយ។ បារាំងបានបញ្ជូននិងចាត់តាំងអ្នករាជការនិងទាហានវៀតណាម ពីប្រទេស



Scanned by CamScanner

វៀតណាម មកឱ្យធ្វើការនៅក្នុងប្រទេសកម្ពុជា ទាំងក្នុងការងាររាជការ ក៏ដូចជាទាំងការងារឯកជន។ បារាំងបានពង្រីកផ្ទៃដីដាំកៅស៊ូនៅខេត្តកំពង់ចាម ដោយពុំទទួលយកប្រជាជនខ្មែរ ឱ្យធ្វើការនៅក្រុមហ៊ុនចំការកៅស៊ូនោះឡើយ។ លើសពីនេះទៀត កម្មករចំការកៅស៊ូទាំងអស់សុទ្ធសឹងជាជនជាតិវៀតណាម និងចិន។ ជាពិសេស ជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបារាំងចាត់តាំងឱ្យធ្វើការក្នុង ការងាររទេសាភិបាលអាណានិគមនិយម។

នយោបាយកេងប្រវ័ញ្ចរបស់បារាំងនេះ បានប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាមូលដ្ឋានសម្រាប់ បញ្ចេញផលិតផលកសិកម្ម។ ក្នុងមួយឆ្នាំៗ គេបាននាំចេញពីប្រទេសកម្ពុជា នូវជ័រកៅស៊ូប្រមាណពី១៥ ទៅ២០ពាន់តោន អង្ករពី១៥០ទៅ២០៥ពាន់តោន គ្រាប់ពោតពី៣០០ទៅ៤០០ពាន់តោន ហើយនិងផលិតផលកសិកម្មផ្សេងៗទៀតជាច្រើន។

នៅចុងទសវត្សទី៤០នៃសតវត្សទី២០ ប្រទេសកម្ពុជា ស្ថិតនៅជាប្រទេសកសិកម្មអន់ថយនៅឡើង ហើយជាប្រទេសមួយមានរោងចក្រតិចតួចស្តួចស្តើងបំផុត ក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីភាគ អាគ្នេយ៍។ ក្នុងឋានៈជាប្រទេសកសិកម្ម កម្ពុជាមានតែរោងចក្រឧស្សាហកម្មសម្រាប់ផលិតឧបករណ៍កសិកម្មតែមួយគត់។

ចំពោះពន្ធអាករវិញ បារាំងបានយកពន្ធដី និងការតម្លើងពន្ធដារ សព្វសារពើពីកសិករក្រីក្រខ្មែរ ដោយបង្កើតឱ្យមានពន្ធដារគ្រប់បែបយ៉ាង រួមទាំងបង្កើតឱ្យមានពន្ធមនុស្សទៀតផង មនុស្សម្នាក់ត្រូវបង់ពន្ធពី២,៥០រក្នុងមួយឆ្នាំ លុះដល់ឆ្នាំ១៩២៨ ពន្ធនេះបានឡើងដល់៩,៤០រ ក្រៅពីនេះ មានពន្ធលើសត្វពាហនៈ លើដំណាំ លើផ្ទះសម្បែង និងពន្ធលើទូកនេសាទជាដើម ដោយមិនគិតដល់ពន្ធមិនចំពោះ ដែលមានទឹកប្រាក់ច្រើនជាងពន្ធផ្ទាល់រាប់សិបដង។ ពន្ធអាករពីមុន ព្រះរាជាខ្មែរបង្គាប់ឱ្យមន្ត្រីខ្មែរដើរប្រមូល នៅពេលបារាំងដើរប្រមូលជុំនួសវិញ ត្រូវបានបង្កើនយ៉ាងខ្លាំង។ នេះជាការគាបសង្កត់របស់បារាំង ធ្វើឱ្យកើតមានតម្រូវការក្នុងប្រទេសនូវរូបិយប័ណ្ណថ្មី។ ការបញ្ចូលរូបិយប័ណ្ណអាណានិគម ដែលមានតម្លៃខ្ពស់ធ្វើឱ្យតម្លៃប្រាក់រៀលខ្មែរធ្លាក់ចុះ។ ពន្ធអាករខ្យល់ហួសហេតុ ហើយពេលខ្លះប្រជាពលរដ្ឋខ្មែរមិនអាចប្រាក់បង់ពន្ធរួចឡើយ។ ក្រៅពីពន្ធដារ ប្រជាជនម្នាក់ៗត្រូវជាប់កំណែនចំនួន២ខែក្នុងមួយឆ្នាំ។

នៅពេលចុះទារពន្ធម្តងៗ រដ្ឋការបារាំងបានប្រើអំពើឃោរឃៅយ៉ាងខ្លាំង ដោយប្រើមធ្យោបាយដូចជាដាក់គំនាបកៀបសង្កត់បង្ខំឱ្យប្រជាជនកម្ពុជាបង់ពន្ធជាកំហិត ក្នុងករណីគេចវេសមិនព្រមបង់ពន្ធ បារាំងធ្វើទារុណកម្មមកលើប្រជាជនខ្មែរយ៉ាងព្រៃផ្សៃជាទីបំផុត។ អំពើឃោរឃៅរបស់បារាំងនាំឱ្យកើតមានការបះបោរប្រឆាំងនឹងបារាំងវិញ ដូចជាចលនាបះបោរប្រឆាំងបារាំងរបស់ប្រជាជននៅភូមិតិរិច្ឆាន ឃុំក្រាំងលាវ ស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំង។

ចលនាប្រឆាំងនឹងបារាំងក៏បានផ្ទុះឡើងនៅឆ្នាំ១៩៤២ ប្រទេសកម្ពុជា បានបង្កើតរណសិរ្ស " ខ្មែរឥស្សរៈ " រីឯប្រទេសវៀតណាមបានបង្កើតរណសិរ្ស " វៀតមិញ "។ ក្រោមការដឹកនាំរបស់កុម្មុយនីស្តឥណ្ឌូចិន ខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាសកម្ម ទោះបីពុំទាន់បានកសាងមូលដ្ឋានរបស់ខ្លួនឱ្យបានរឹងមាំក៏ដោយ។ ក្រោយមកប្រទេសកម្ពុជា បានបង្កើតការិយាល័យបក្សកុម្មុយនីស្តឥណ្ឌូចិន និងបង្កើតគណៈកម្មាធិការកម្មករកម្ពុជា។ បក្សកុម្មុយនីស្តឥណ្ឌូចិន មានឥទ្ធិពលខ្លាំងមកលើចលនារំដោះជាតិនៅកម្ពុជា។ បក្សប្រជជនបដិវត្តខ្មែរបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ក្រោមកា



Scanned by CamScanner

រដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ការស៊ូក្នុងចន្លោះពីឆ្នាំ១៩៥១-១៩៥៤ មានលក្ខណៈមួយគម្រាមកំហែងដល់របបអាណានិគមនិយមបារាំងនៅទូទាំងឥណ្ឌូចិន និងជាកម្លាំងសង្កត់យ៉ាងខ្លាំងចំពោះបារាំង ហើយបង្ខំឱ្យបារាំងត្រូវពិនិត្យឡើងវិញនូវយុទ្ធសាស្ត្ររបស់ខ្លួននៅកម្ពុជា។ ដោយសារចលនាប្រឆាំងនឹងបារាំងនៅកម្ពុជា មានទំហំធំធេងខ្លាំងឡើងៗនៅទូទាំងប្រទេស លុះដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ បារាំងបានប្រគល់ឯករាជ្យដល់ប្រជាជនកម្ពុជា។

បន្ទាប់ពីទទួលបានឯករាជ្យពីបារាំង ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ ជាប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា បានកសាងខឿនសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន និងកិត្តិនាមប្រទេសកម្ពុជា មានភាពល្បីរន្ទឺទូទាំងតំបន់អាស៊ី។ ភាពល្បីល្បាញរបស់ប្រទេសកម្ពុជា ក៏បានធ្លាក់ចុះមកវិញបន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បង្កឡើងដោយពួកស្តាំនិយម មាននិន្នាការប្រឆាំងនឹងរបបរាជានិយមនៅកម្ពុជា។

លោកសេនាប្រមុខ លន់ ណុល ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ បានប្រកាសរដ្ឋាភិបាលរបស់លោកថា ជារដ្ឋាភិបាលស្របច្បាប់ដោយមានឈ្មោះថា "សាធារណរដ្ឋខ្មែរ "។ មកដល់ត្រង់ចំណុចនេះ មានបញ្ហាជាច្រើនបានលើកឡើងថា ហេតុអ្វីបានជារដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ប្រកាសយ៉ាងប្រញាប់ប្រញាលម្លេះ? បង្ហាញឱ្យឃើញថា រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មានគោលដៅធំពីរគឺ ÷

ដើម្បីកេសម្លេងគាំទ្រយ៉ាងពេញទំហឹងពីស.រ.អ. និងឱ្យស.រ.អ. ជួយផ្តល់ជំនួយយោធា ដើម្បីប្រឆាំងនឹងពួកកុម្មុយនីស្ត។ ហេតុនេះបានជាលោក លន់ ណុល ទាក់ទងទៅរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន ដើម្បីស្នើឱ្យទីបញ្ជាការស.រ.អ. វាយលុកលើទឹកដីនៃតំបន់រំដោះក្នុងប្រទេសកម្ពុជានិងឡាវ ក្នុងករណីមានការចាំបាច់ខាងយោធាហើយស្នើឱ្យស.រ.អ. ផ្តល់ជំនួយយោធាចូលមកក្នុងប្រទេសកម្ពុជា" ទប់ទល់នឹងកម្លាំងតស៊ូរបស់សម្តេចនរោត្តមសីហនុ និងវៀតណាម។

ទំនាក់ទំនងនយោបាយរវាងសាធារណរដ្ឋខ្មែរ និង សហរដ្ឋអាមេរិក ធ្វើឡើងសម្រាប់សុំជំនួយយោធាពីសហរដ្ឋអាមេរិក ដើម្បីទប់ទល់នឹងការគម្រាមកំហែងពីក្រុមខ្មែរក្រហម ដែលមានប្រទេសចិននៅពីក្រោយខ្នងដ៏មហិមាផង និងដើម្បីទប់ទល់នឹងចលនាតស៊ូរបស់សម្តេចនរោត្តមសីហនុផង។

យន្តហោះបេ៥២ ចាប់ផ្តើមទម្លាក់គ្រាប់បែកយ៉ាងខ្លាំងលើមូលដ្ឋានសឹកខ្មែរវៀតកុង។ ហើយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ សហការណ៍ជាមួយវៀតណាមខាងត្បូង វាយរំលំកម្លាំងអ្នកតស៊ូខ្មែរ និងវៀតណាមកុម្មុយនីស្តនៅកម្ពុជា។ បន្ទាប់ពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បានកាត់ទោសប្រហារជីវិតសម្តេចនរោត្តមសីហនុ កំបាំងមុខតាមរយៈរដ្ឋសភារបស់ខ្លួន។ ជម្លោះរវាងសម្តេច សីហនុ និងលោក លន់ ណុល បានកើតឡើងចំណែករដ្ឋសភាជាតិបានធ្វើការចោទ សម្តេចនរោត្តមសីហនុ ថាបានរួមគំនិតបើកឱ្យមានវៀតណាមកុម្មុយនីស្ត ប្រើប្រាស់ទឹកដីប្រទេសកម្ពុជា នឹងអនុញ្ញាតឱ្យកងទ័ពវៀតណាមខាងជើង និងវៀតកុងឈប់សំចតនៅលើទឹកដីខ្មែរថាជា "អំពើក្បត់ជាតិ" ព្រមទាំងបំផុសឱ្យមានបាតុកម្មជាសាធារណៈមួយប្រឆាំងនឹងសម្តេចព្រះនរោត្តមសីហនុ ហើយប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅតាមព្រំដែនកម្ពុជា។

របបសាធារណរដ្ឋខ្មែរ បានផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាម ហើយបានស្នើឱ្យក្រុង ហាណូយ ដកកងទ័ពទាំងអស់របស់ខ្លួនចេញពីកម្ពុជា ក្នុងរយៈពេល៤៨ម៉ោងជាកំហិត គឺថាឱ្យអស់មុន ថ្ងៃទី១៥មីនា១៩៧០។ លោក លន់ ណុល បំផុសអ្នកគាំទ្ររូបលោក ឱ្យត្រៀមរៀបចំបាតុកម្ម



Scanned by CamScanner

ប្រឆាំងនឹង "ការឈ្លានពានជាយថាហេតុណាមួយ" របស់វៀតណាមរួចស្រេចទៅហើយ។ គ្រប់ស្ថាប័នរដ្ឋត្រូវបានឈប់សម្រាកដើម្បីត្រៀមធ្វើបាតុកម្ម។ ក្នុងជួរសិស្សានុសិស្ស បានរៀបចំលើកបដាជាច្រើនមានពាក្យស្លោកប្រឆាំងនឹងពួកវៀតណាមខាងជើងនិងពួកវៀតកុង។ សិស្សសាលារាប់ពាន់នាក់ បានដើរតម្រង់ទៅរដ្ឋសភាជាតិ អមដោយសម្រែកតាមចង្វាក់ជាភាសាខ្មែរ បារាំងនិងអង់គ្លេស ថា "បរាជ័យពួកវៀតកុងនិងវៀតណាមខាងជើង" " វៀតកុងត្រឡប់ទៅប្រទេសឯងវិញទៅ" "កម្ពុជាពុំមែនជាទឹកដីរបស់វៀតមិញទេ"។

សេចក្តីប្រកាសនេះ បានធ្វើឱ្យប្រជាជនវៀតណាម ដែលកំពុងរស់នៅលើទឹកដីខ្មែរ មានការភិតភ័យ ហើយបានចាកចេញទៅប្រទេសវៀតណាមវិញជាបន្ទាន់ ដោយខ្លាចមានអំពើហិង្សាណាមួយកើត ឡើងជាយថាហេតុដល់អាយុជីវិតរបស់ពួកគេ។ បាតុកម្មប្រឆាំងវៀតណាម នៅមុខរដ្ឋសភាជាតិ បានទាមទារឱ្យមានការដកថយកងទ័ពវៀតកុង និងវៀតណាមខាងជើងចេញពីទឹកដីខ្មែរ។ ដោយលើទឹកចិត្តពីរដ្ឋាភិបាល ពួកបាតុករបានកាប់សម្លាប់ជនជាតិវៀតណាមយ៉ាងរង្គាល និងទាមទារឱ្យមានការផ្តន្ទាទោស អ្នកទាំងឡាយណាដែល "លក់ទឹកដីខ្មែរ "ឱ្យវៀតណាមទៀតផង។

សកម្មភាពរបស់អ្នកប្រឆាំងនឹងយោបាយរើសអើងពូជសាសន៍របស់លោក លន់ ណុល បានដាក់សម្ពាធយ៉ាងខ្លាំងដល់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរឱ្យបញ្ឈប់ជាបន្ទាន់ នូវនយោបាយរើសអើងជាតិសាសន៍ ហើយសកម្មភាពនេះធ្វើឱ្យវៀតណាមមានទឹកចិត្តបន្ថែមទៀត ដោយបានសហការជាមួយកម្លាំងអ្នកតស៊ូខ្មែរ ដើម្បីផ្តួលរំលំមេដឹកនាំរបបសាធារណរដ្ឋខ្មែរ ចេញពីអំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

របបកម្ពុជាប្រជាធិបតេយ្យ បានមកជំនួសរបបសាធារណរដ្ឋខ្មែររបបថ្មីនេះ បានធ្វើឱ្យប្រជាជនកម្ពុជារាប់លាននាក់ បានទទួលរងគ្រោះនិងការកាប់សម្លាប់ មិនតែប៉ុណ្ណោះទំនាក់ទំនងជាមួយប្រទេសជិតខាងត្រូវបានកាត់ផ្តាច់ ពិសេសជាមួយប្រទេសវៀតណាម ដែលជាមិត្តជិតស្និតរបស់របបនេះក៏បានកាត់ផ្តាច់ទំនាក់ទំនងនយោបាយការទូត ហើយបែរជាមើលមុខគ្នាជាសត្រូវនយោបាយទៅវិញ។

ពិភពលោកបានទទួលស្គាល់ថា ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅប្រទេសកម្ពុជាបណ្តាលមកពីការធ្វើអន្តរាគមន៍យោធាពីប្រទេសវៀតណាម។ បន្ទាប់ពីរដ្ឋាភិបាលនៃស.ស.វ និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានសហការគ្នាដាក់ចេញនូវផែនការផ្តួលរំលំមេដឹកនាំ របស់របបកម្ពុជាប្រជាធិបតេយ្យ ចេញពីអំណាចក្នុងឆ្នាំ១៩៧៩។

ក្រោយពីបានទទួលជ័យជំនះ លើរបបកម្ពុជាប្រជាធិបតេយ្យ រដ្ឋាភិបាលវៀតណាមនិងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានឯកភាពគ្នាបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក.) ឡើង ដោយដាក់ឱ្យស្ថិតនៅក្រោមការឧបត្ថម្ភនិងគាំទ្រយ៉ាងពេញទំហឹងពីប្រទេសវៀតណាម។ ពេលនោះទំនាក់ទំនងការទូតរវាងកម្ពុជានិងវៀតណាមបានតភ្ជាប់គ្នាឡើងវិញ ពីមួយថ្ងៃទៅមួយថ្ងៃប្រទេសទាំងពីរបានពង្រឹងនិងពង្រីកចំណងសាមគ្គីភាព មិត្តភាព និងសហប្រតិបត្តិការយូរអង្វែងរវាងរដ្ឋាភិបាលស.ប.ក និង រដ្ឋាភិបាលស.ស.វ។ រដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នា ចុះហត្ថលេខាលើសន្ធិសញ្ញាអន្តរជាតិទ្វេភាគី ក្នុងន័យចងសម្ព័ន្ធភាពគ្នា ដើម្បីផ្លាស់ប្តូរយោបល់គ្នាបង្កើតនូវចំណងសាមគ្គីភាព មិត្តភាពនិងសហប្រតិបត្តិការដ៏យូរអង្វែង ជួយគ្នាទៅវិញទៅមក និងស្តារឡើងវិញ នូវលើ



Scanned by CamScanner

វិស័យធំពីរគឺ នយោបាយ និងសេដ្ឋកិច្ច ចាប់ពីពេលនោះមកទំនាក់ទំនងនយោបាយរបស់ប្រទេសទាំងពីរ ឡើងដល់កំពូលជាងពេលណា ទាំងអស់ក្នុងប្រវត្តិសាស្ត្រនៃទំនាក់ទំនងរបស់ខ្លួន។

វិស័យនយោបាយ រដ្ឋាភិបាលទាំងពីរបានពង្រឹងទំនាក់ទំនងចរិតនយោបាយខ្លាំង ជាងចរិតសេដ្ឋកិច្ច ព្រោះសម្ព័ន្ធភាពនៃប្រទេសទាំងពីរកម្ពុជានិងវៀតណាម មានគោលដៅដ៏ចំបងគឺការពារសមិទ្ធផលរដ្ឋ ដែលរំដោះបានពីរបបកម្ពុជាប្រជាធិបតេយ្យ ប្រគល់ជូនក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដែលវៀតណាមចាត់ទុកថា ជារដ្ឋាភិបាលតែមួយគត់កើតចេញពីប្រជាជនកម្ពុជា មានចរិតសាមគ្គីភាពទូលាយជាមួយប្រទេសជិតខាងពិសេសជាមួយវៀតណាមប្រសើរជាងរដ្ឋាភិបាលមុនៗ។

ចំណែកឯ វត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា ដើរតួនាទីជាអ្នកការពារសន្តិសុខរបស់ប្រជាជនកម្ពុជា ឱ្យរួចផុតពីការគម្រាមកំហែងរបស់ពួកខ្មាំងខ្មែរក្រហមផង និងការពារអាយុជីវិតរបស់រដ្ឋាភិបាលក្រុងភ្នំពេញផង។ ព្រោះសុខភាពនយោបាយរបស់រដ្ឋាភិបាលក្រុងភ្នំពេញនាពេលនោះមានភាពទុនខ្សោយនៅឡើយ បើគ្មានវត្តមានកងទ័ពវៀតណាមនៅពីក្រោយទេ នោះរដ្ឋាភិបាលនេះនឹងស្លាប់។

១០ឆ្នាំក្រោយការដួលរលំរបបខ្មែរក្រហម ទំនាក់ទំនងកម្ពុជា-វៀតណាម គឺជាការចាំបាច់បំផុត ដែលមិនអាចខ្វះបាន។ ទោះបីជាមានការរិះគន់ពីអន្តរជាតិ ពិសេសពីប្រទេសលោកខាងលិចនិងសម្ព័ន្ធមិត្តរបស់គេយ៉ាងណាក្តី ក៏ប្រទេសកម្ពុជានិងវៀតណាម រក្សាចំណងសាមគ្គីភាពរវាងប្រទេសទាំងពីរបានយ៉ាងស្អិតរមួត លើសពីនេះទៀតប្រទេសទាំងពីរ បានពង្រឹងចំណងមិត្តភាព ជាមួយបណ្តាប្រទេសកុម្មុយនីស្តនៅអឺរ៉ុបខាងកើត និងបណ្តាលប្រទេសមិនចូលបក្សសម្ព័ន្ធនៅទ្វីបអាហ្វ្រិកមួយចំនួនទៀត ដើម្បីសហការគ្នាការពារការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា។

ទំនាក់ទំនងអន្តរជាតិរវាងកម្ពុជានិងវៀតណាម ធ្វើឡើងស្របទៅនឹងសន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ អត្ថន័យនៃសន្ធិសញ្ញានេះ ធ្វើឡើងដើម្បីជួយសង្គ្រោះគ្នាទៅវិញទៅមក ឈរលើស្មារតីអន្តរជាតិអធន និងជាប្រទេសជិតខាងគ្នាល្អ វៀតណាមត្រូវតែបំពេញកាតព្វកិច្ចនេះ ដោយឥតងាករេ ដើម្បីការពារនិងពង្រីកមិនឈប់ឈរនូវប្រពៃណី យុទ្ធសាមគ្គីភាព ការទាក់ទងប្រកបដោយមិត្តភាព និងកិច្ចសហប្រតិបត្តិការជាភាតរៈ ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក លើគ្រប់វិស័យឈរលើមូលដ្ឋានគោរពឯករាជភាព អធិបតេយ្យភាពរបស់ផងគ្នា គោរពផលប្រយោជន៍ដ៏សុច្ចរិតរបស់គ្នា មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នា ស្មើភាពនិងមានផលប្រយោជន៍ទៅវិញទៅមករវាងកម្ពុជានិងវៀតណាម។

នេះមូលហេតុ ដែលនាំឱ្យទំនាក់ទំនងកម្ពុជា-វៀតណាម ឈានឡើងដល់កំរិតខ្ពស់។ គួររំលឹកដែរថាទំនាក់ទំនងកម្ពុជានិងវៀតណាម មានប្រវត្តិដ៏យូរលង់មកហើយ ប៉ុន្តែទំនាក់ទំនងនយោបាយជាផ្លូវការរវាងកម្ពុជានិងវៀតណាមបង្កើតឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៧។ លក្ខណៈរួមនៃទំនាក់ទំនងនៃប្រទេសទាំងពីរមានបញ្ហាធំពីរគឺ ទីមួយ ប្រទេសទាំងពីរស្ថិតនៅក្រោមនឹមអាណានិគមនិយម ចក្រពត្តិនិយមដូចគ្នា។ ទីពីរ ធ្លាប់មានប្រវត្តិតស៊ូប្រឆាំងនឹងអាណានិគមនិយម ចក្រពត្តិនិយមជាប្រទេសដាក់នឹមត្រួតត្រាមកលើប្រទេសទាំងពីរដូចគ្នា ក៏ដូចជាបណ្តាលប្រទេសទាំងបី នៅឥណ្ឌូចិនទាំងមូល។



Scanned by CamScanner

ឈរលើលក្ខការណ៍ កិច្ចការពារនិងកសាងប្រទេសខ្លួន គឺជាការងាររបស់ប្រជាជននៃប្រទេសនីមួយៗ ភាគីទាំងពីរសន្យាថា និងយកអស់កម្លាំងកាយរបស់ខ្លួនដើម្បីជួយឧបត្ថម្ភគ្នាទៅវិញទៅមកលើគ្រប់វិស័យនិងគ្រប់រូបភាពចាំបាច់ ដើម្បីបង្កើនសមត្ថភាព ការពារឯករាជ្យ អធិបតេយ្យ ឯកភាពបូរណភាពដែនដី និងពលកម្មសន្តិភាពនៃប្រទេសនីមួយៗ ប្រឆាំងរាល់ឧបាយកលនឹងអំពើបំផ្លិចបំផ្លាញរបស់បណ្តាលចក្រពត្តិ និងប្រតិកិរិយាអន្តរជាតិ។

បន្ទាប់ពីប្រទេសកម្ពុជា មាននយោបាយអន្តរជាតិនិយកម្ម ជាមួយប្រទេសជិតខាងខ្លួនល្អ កម្ពុជាបានជួបនូវ វិបុលសុខ ភាពសុខសាន្ត និងនាំមកនូវការអភិវឌ្ឍលើវិស័យនយោបាយ និងសេដ្ឋកិច្ចអន្តរជាតិ។ ការធ្វើទំនាក់ទំនងល្អ ជាមួយប្រទេសជិតខាងខ្លួន គឺជាការបើកនូវទំព័រប្រវត្តិសាស្ត្រថ្មី សម្រាប់នាំកម្ពុជាឱ្យឆ្លងផុតពីគ្រោះមហន្តរាយ និងសង្គ្រាមស៊ីវិលដ៏ហិនហោច។

ក្នុងនិក្ខេបបទនេះ ចែកចេញជា៥ជំពូក។ <u>ជំពូកទី១</u> សិក្សាពីទិដ្ឋភាពនៃប្រវត្តិទំនាក់ទំនងកម្ពុជា-វៀតណាម ដើម្បីយកមកធ្វើជាទ្រឹស្តីឆ្លុះបញ្ចាំងពីទំនាក់ទំនងនយោបាយនៃប្រទេសទាំងពីរ ក្នុងដែនកំណត់របស់និក្ខបបទនេះ។ ពីឆ្នាំ១៩១០ រហូតទៅដល់ឆ្នាំ១៩៣០ អាស៊ីភាគអាគ្នេយ៍ទាំងមូលបានជួបប្រទះនូវការប្រែប្រួលមួយដ៏ធំ ដោយសារចរន្តមនោគមវិជ្ជាធំៗពីរ ហើយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រវត្តិសាស្ត្រនៃភូមិភាគនេះនិងពិភពលោក។ ចរន្តមនោគមវិជ្ជាទាំងពីរនោះគឺ ៖

ទីមួយ ៖ ចរន្តនៃចលនាជាតិនិយម ដែលមានផ្តើមកំណើតដំបូងក្នុងប្រទេស រួចហើយផ្សព្វផ្សាយ ពេញទាំងអាស៊ីចុងបូព៌ារហូតដល់អាស៊ីភាគអាគ្នេយ៍។ គំនិតជាតិនិយមនេះ បង្កើតជាចលនានយោបាយ ប្រយុទ្ធប្រឆាំងនឹងអាណានិគមបរទេស។ ការតស៊ូរបស់ពួកជាតិនិយមប្រឆាំងនឹងពួកអាណានិគមបស្ចិមប្រទេស ដែលកំពុងកៀបសង្កត់ជិះជាន់ដាក់នឹមត្រួតត្រាលើជនជាតិក្នុងទ្វីបអាស៊ី។

ទីពីរ ៖ ចរន្តនៃគំនិតប្រជាធិបតេយ្យលាយជាមួយគំនិតសង្គមនិយម។ គំនិតឬចរន្តទី២នេះច្រើនបាននិស្សិតនិងបញ្ញាវ័ន្តជាតិអាស៊ី ដែលបានទៅសិក្សាក្នុងបណ្តាប្រទេសនានានៅអឺរ៉ុប និងនៅអាមេរិក នាំចូលមកក្នុងមាតុប្រទេសរបស់ខ្លួនវិញ កាលបើគេបានបញ្ចប់ការសិក្សានៅបរទេសរួចមក។

ក្នុងនោះក៏មាននិស្សិតនិងបញ្ញាវ័ន្តរបស់ប្រទេសទាំងបី នៅឧបទ្វីបឥណ្ឌូចិនបាននាំគំនិតប្រជាធិបតេយ្យពីបរទេសចូលមកតំបន់នេះដែរ បើតាមអ្នកជំនាញខាងភូមិសាស្ត្រគឺ លោក ម៉ាល់ត៍ប្រុងដែល បានរៀបចំបង្កើតពាក្យ " ឥណ្ឌូចិន " សម្រាប់សំគាល់លក្ខណៈនៃស្នើរកោះ ដែលខណ្ឌចែកឈូងសមុទ្រ តុងគឹង ពីឈូងសមុទ្រសៀម នៅសងខាងជួរភ្នំអណ្ណាម ដែលសមាគមរដ្ឋឥណ្ឌូចិនដែលលោក ដឺហ្គោលបានប្រកាសបង្កើត នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៤៩ មានឈ្មោះជាផ្លូវការថា " សហភាពឥណ្ឌូចិនបារាំង" ហើយត្រូវផ្សំឡើងដោយរដ្ឋ៥ គឺ តុងកឹង អណ្ណាម កូសាំងស៊ីន លាវ និងកម្ពុជា។ ដោយមានការបែងចែកដាច់ស្រឡះពីឈ្មោះទីបី ដែលចេញពីគម្រោងនៃអង្គការកុម្មុយនីស្តអន្តរជាតិ របស់សហភាពសូវៀត ថា "សហព័ន្ធឥណ្ឌូចិន"។

បើតាមលោក ម៉ាល់ត៍ ប្រុងដែល សហភាពឥណ្ឌូចិន មានន័យសម្រាប់សំគាល់ពាក្យ ដែនដីដែលអាណានិគមបារាំងធ្លាប់ធ្វើអាណានិគមមកលើ ចំពោះពាក្យថា សហព័ន្ធឥណ្ឌូចិន ជាបញ្ញត្តិសម្រាប់សំគាល់របស់អង្គការកុម្មុយនីស្តអន្តរជាតិ ដូចជាសហព័ន្ធស្តង់ឌីណាវ ឬ សហព័ន្ធបាល់កង់ជាដើម។ បន្ទាប់ពីការចូលធ្វើអាណានិគមរបស់បារាំងលើប្រទេសកម្ពុជា វៀតណាមនិងឡាវ។ រដ្ឋាភិបាល



Scanned by CamScanner

បារាំងប្រមូលផ្តុំប្រទេសទាំងបី ជាដែនដីមួយអាណានិគមតែមួយដែលមានឈ្មោះថា " ឥណ្ឌូចិនបារាំង " ហើយស្ថិតនៅក្រោមការត្រួតត្រារបស់អគ្គទេសាភិបាលបារាំង។

ឥណ្ឌូចិនគឺ ជាតំបន់ពិសេសរបស់បារាំងសម្រាប់ក្រកេកោគទ្រព្យ ធម្មជាតិ ដែលបម្រើដល់វិស័យឧស្សាហកម្ម ក្នុងនោះមានវិស័យពីរ ដែលបានផ្តល់ទុនច្រើនជាងគេគឺ កៅស៊ូ និងការយករ៉ែត្បូងថ្ម ត្រូវបានបារាំង ដឹកយកទៅប្រទេសរបស់ខ្លួនយ៉ាងពេញទំហឹង។ ក្នុងវិស័យឧស្សាហកម្ម បារាំងបានពង្រីករោងចក្រជាច្រើននៅប្រទេសវៀតណាម ដូចជា រោងចក្រអំបោះ ស្រា ឈើគូស ស្ករស ម៉ាស៊ីនកិនស្រូវ ជួសជុលរថយន្ត កប៉ាល់និងរោងចក្រអគ្គិសនីជាដើម ពេលនោះឥណ្ឌូចិន បានក្លាយជាទីផ្សារផ្លាស់ប្តូរទំនិញចេញ-ចូលយ៉ាងសំខាន់របស់បារាំង។

ចំពោះពន្ធអាករវិញ បារាំងបានយកពន្ធដី និងការតម្លើងពន្ធដារ សព្វសារពើពីកសិករក្រីក្រខ្មែរ ដោយបង្កើតឱ្យមានពន្ធដារគ្រប់បែបយ៉ាង រួមទាំងបង្កើតឱ្យមានពន្ធមនុស្សទៀតផង មនុស្សម្នាក់ត្រូវបង់ពន្ធពីរ ២,៥០៛ ក្នុងមួយឆ្នាំ។ លុះដល់ឆ្នាំ១៩២៨ ពន្ធនេះបានឡើងដល់៩,៥០៛ ក្រៅពីនេះមានពន្ធលើសត្វពាហនៈ ពន្ធលើដំណាំ ពន្ធលើផ្ទះសម្បែង និងពន្ធលើទូកនេសាទជាដើម ដោយមិនគិតដល់ពន្ធមិនចំពោះ ដែលមានទឹកប្រាក់ច្រើនជាងពន្ធផ្ទាល់រាប់សិបដងផង។ ក្រៅពីពន្ធដារ ប្រជាជនម្នាក់ៗត្រូវជាប់កំណែនចំនួន២ខែក្នុងមួយឆ្នាំ។

ផ្តើមចេញពីចំណុចនេះ ទើបមានចលនាបដិវត្តន៍របស់ប្រទេសទាំងបី បានក្រោកឈរឡើងប្រឆាំងនឹងបារាំងក្រោមការដឹកនាំរបស់លោក ហូ ជីមិញ ( Ho Chi Minh ) ដោយមានការចូលរួមយ៉ាង ស្រស្រាក់ស្រស្រាំពីវណ្ណៈកសិករនិងកម្មករ ហើយចលនានេះ បានផ្ទុះឡើងយ៉ាងសកម្មទូទាំងតំបន់ឥណ្ឌូចិនទាំងមូល ដោយមានសន្ទុះយ៉ាងខ្លាំង ហើយឈានទៅដល់ការតស៊ូប្រដាប់អាវុធ រហូតបានទាំឯករាជ្យពីបារាំង ជូនប្រជាជាតិនីមួយៗនៅឥណ្ឌូចិនវិញ។ លោក ផាម វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាមខាងជើង បានបញ្ជាក់យ៉ាងច្បាស់ស្តីអំពីការទទួលស្គាល់ លើបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា។ សម្តេចនរោត្តមសីហនុ ដោយឈរលើទស្សនៈជាតិនិយមរបស់ព្រះអង្គ បានធ្វើសេចក្តីអះអាងមុនពេលធ្វើរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ថា "បើសិនជាលោកប្រធានាធិបតី និច សុន មិនកែមធ្យោបាយ ដើម្បីដកកងទ័ពអាមេរិក ចេញពីភូមិភាគអាស៊ីអាគ្នេយ៍ ខ្ញុំយល់ថា គឺមានការកៀបសង្កត់ពីមហាអំណាច "។

ក្នុងដំណាក់កាលនេះ យើងឃើញថា ទំនាក់ទំនងនយោបាយរវាងកម្ពុជានិងវៀតណាមហាក់ដូច ជាល្អល្អូកល្អើននឹងគ្នា ភាគីវៀតណាមបានប្រកាសយ៉ាងច្បាស់។ លោក ផាម វ៉ាន់ដុង បានអះអាងថា " គោរពឯករាជ្យភាពសន្តិភាព អព្យាក្រិតភាព អធិបតេយ្យភាព និងរបបនយោបាយរបស់ប្រជាជនកម្ពុជា ទទួលស្គាល់និងមានកាតព្វកិច្ចគោរពនូវអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា ដែលមានព្រំប្រទល់ដូចបច្ចុប្បន្ននេះ "។

<u>ជំពូក២</u> សិក្សាពីបុព្វបទនៃទំនាក់ទំនងកម្ពុជា-វៀតណាម ក្នុងជំពូកនេះគឺកេឲ្យឃើញពីការភាពខ្លាំងនិងភាពខ្សោយ នៃទំនាក់ទំនងនយោបាយរបស់ប្រទេសទាំងពីរ ដើម្បីធ្វើជាបទពិសោធន៍ជាប្រវត្តិសាស្ត្រក្នុងការរីតចំណងនយោបាយជាមួយប្រទេសជិតខាងទៀត មានលក្ខណៈស្មើមុខមាត់គ្នា និងគោរពគ្នាទៅវិញទៅមក។



Scanned by CamScanner

បុព្វបទនៃទំនាក់ទំនងកម្ពុជា-វៀតណាម នៅប្រទេសចិនក្នុងឆ្នាំ១៩៥២ លោក ហូ ជីមីញ និងជនជាតិវៀតណាមខ្លះទៀត ដែលស្នាក់នៅប្រទេសចិន បានរួមគំនិតគ្នាបង្កើត "សមាគមយុវជនបដិវត្តន៍" (Association of Revolutionary Youth)មួយឡើង និងសារពត៌មានមួយទៀត ដែលមានឈ្មោះថា "យុវជន"។ សមាគមនេះបានចូលរួមជាមួយនឹងគណបក្សកុម្មុយនីស្តវៀតណាមផ្សេងៗទៀត ដើម្បីបង្កើតជាគណបក្សកុម្មុយនីស្តធំមួយ ឈ្មោះគណបក្សកុម្មុយនីស្តឥណ្ឌូចិន (Indochinese Communist Party) សរសេរកាត់ថា "I.C.P"។ គណបក្សកុម្មុយនីស្តឥណ្ឌូចិននេះ បានដាក់កម្មវិធីនយោបាយពីរយ៉ាងគឺ៖

-គោលដៅជាតិនិយម ដើម្បីស្វែងរកឯករាជ្យភាព

-គោលដៅកុម្មុយនីស្ត ដើម្បីធ្វើបដិវត្តន៍សង្គមនិយម

នៅឆ្នាំ១៩៣៩ សង្គ្រាមលោកលើកទី២បានផ្ទុះឡើង ហើយរដ្ឋាភិបាលបារាំងរំលាយគណបក្សកុម្មុយនីស្តឥណ្ឌូចិនចោលទៅវិញ ហាមប្រាមមិនឱ្យចេញសៀវភៅ និងសារព័ត៌មាន និងចាប់ចងសមាជិកគណបក្សកុម្មុយនីស្ត ជាងពីរពាន់នាក់ដើម្បីជាការព្រមាន។ មេដឹកនាំគណបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលនៅសេសសល់បានរត់គេចលាក់ខ្លួនម្តងទៀត ហើយបានប្រកាសការតស៊ូរំដោះជាតិ ដោយឈរលើជំហរនយោបាយប្រាកដនិយមមួយយ៉ាងច្បាស់លាស់បំផុត ដោយខ្សែកចំពោះកម្មវិធីបដិវត្តន៍កុម្មុយនីស្ត ត្រូវរង់ចាំរហូតដល់ក្រោយពេលវៀតណាមបានទទួលឯករាជ្យសិន។ លោក ហូ ជីមិញ បានធ្វើដំណើរទៅកាន់ ប្រទេសចិនជាថ្មីម្តងទៀត ដើម្បីរង់ចាំឱកាសល្អ ធ្វើការវាយប្រយុទ្ធប្រឆាំងនឹងបារាំងជាថ្មីឡើងវិញ ម្តងទៀត នៅក្នុងខណៈពេលដែលតំបន់ឯទៀតក្នុងប្រទេសវៀតណាម កំពង់ស្ថិតនៅក្នុងភាពស្ងាត់ស្ងៀម ហើយរង់ចាំធ្វើសង្គ្រាម។

បក្សកុម្មុយនីស្តឥណ្ឌូចិន បានវិភាគយ៉ាងត្រឹមត្រូវ អំពីទំនាក់ទំនងរវាងឯករាជ្យជាតិ នៃប្រទេស នីមួយៗ និងសម្ព័ន្ធប្រយុទ្ធជាចាំបាច់នៃប្រជាជាតិទាំងបីនៅឥណ្ឌូចិន។ បក្សកុម្មុយនីស្តឥណ្ឌូចិនមានចក្ខុវិស័យដ៏វែងឆ្ងាយ ដោយមើលឃើញថា ៖ នៅឥណ្ឌូចិន " ពុំមានប្រជាជាតិណាមួយត្រូវបានរំដោះដាច់តែឯងទេ ព្រោះថាតំបន់ឥណ្ឌូចិន ស្ថិតនៅក្រោមការត្រួតត្រាតែមួយរបស់អាណានិគមបារាំង ក្នុងវិស័យបី ធំៗគឺ ៖ វិស័យនយោបាយ សេដ្ឋកិច្ច និងយោធា "។

ប្រទេសទាំងបី របស់បក្សកុម្មុយនីស្តឥណ្ឌូចិន ត្រូវតែរឹតចំណងមហាសាមគ្គីឱ្យទៅជាកម្លាំងចលករតែមួយ ទើបអាចរើខ្លួនរួចផុតពីការជិះជាន់របស់បរទេសឈ្លានពាន។ មានន័យថា ចលនារំដោះជាតិរបស់ប្រជាជននៃប្រទេសទាំងបីត្រូវតែផ្សារភ្ជាប់គ្នា ហើយពឹងពាក់គ្នាទៅវិញទៅមក។ តែសម្ព័ន្ធភាពនៃប្រជាជនទាំងបី ពុំចាំបាច់រួមបញ្ចូលប្រទេសទាំងបី បង្កើតជារដ្ឋរួមតែមួយនោះទេ អាស្រ័យហេតុនេះ ប្រជាជនកម្ពុជា ឡាវនិងវៀតណាម ត្រូវតែមានឯករាជ្យរៀងៗខ្លួន មានសិទ្ធិដោះស្រាយវាសនាជាតិខ្លួនដោយខ្លួនឯង ទៅតាមការយល់ឃើញនិងធ្វើតាមឆន្ទៈរបស់ខ្លួន និងចេះបត់បែនតាមស្ថានការ នៅតាមកាលៈទេសនៃស្ថានភាពរបស់ប្រទេសនីមួយៗ "។

រីឯក្បាលម៉ាស៊ីនដឹកនាំបក្សកុម្មុយនីស្តឥណ្ឌូចិន មានគោលការណ៍ធំៗពីរយ៉ាង សំដៅទៅលើទិសដៅនយោបាយរបស់ខ្លួន៖

- ការកសាងរដ្ឋឥណ្ឌូចិនតែមួយ



Scanned by CamScanner

- ការកសាងរង្វង់សហព័ន្ធ ដែលមានឯករាជ្យភាពលើទស្សនៈវិស័យនយោបាយនិងមនោគមវិជ្ជា។

នៅឆ្នាំ១៩៤២ ប្រទេសកម្ពុជាបានបង្កើតរណសិរ្ស " ខ្មែរឥស្សរៈ " រីឯប្រទេសវៀតណាមបានបង្កើតរណសិរ្ស "វៀតមិញ"។ ក្រោមការដឹកនាំរបស់កុម្មុយនីស្តឥណ្ឌូចិន ខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាងសកម្ម ទោះបីពុំទាន់បានកសាងមូលដ្ឋានរបស់ខ្លួនឱ្យបានរឹងមាំក៏ដោយ។ ក្រោយមកកម្ពុជាបានបង្កើតការិយាល័យបក្សកុម្មុយនីស្តឥណ្ឌូចិន និងបង្កើតគណៈកម្មាធិការកម្មករកម្ពុជា។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ បក្សប្រជាជនបដិវត្តខ្មែរបានបង្កើតឡើង។

ខ្មែរឥស្សរៈចាប់ផ្ដើមធ្វើសកម្មភាពយ៉ាងសកម្មលើផ្ទៃប្រទេស និងក្នុងតំបន់រំដោះ។ ជាមួយគ្នានោះ កងទ័ពវៀតណាមខាងជើង បានចូលមកដល់ប្រទេសកម្ពុជា ធ្វើឱ្យការប្រយុទ្ធប្រឆាំងនឹងបារាំងកាន់តែខ្លាំងក្លាឡើង ហើយបានកសាងទីតាំងរបស់ខ្លួនកាន់តែធំឡើងៗ រហូតពង្រីងតំបន់កាន់កាប់របស់ខ្លួនបាន១/៣ នៃផ្ទៃប្រទេស។ ខ្មែរឥស្សរៈបានចាប់ផ្ដើមធ្វើមីទ្ទេងស្ដីពី ឯករាជ្យជាតិ និងបង្កើតរណសិរ្ស ឯករាជ្យកម្ពុជា ដែលដឹកនាំដោយខ្មែរកុម្មុយនីស្ដ ពីររូបគឺលោក ទូ សាមុត និងលោក ស៊ឹង ង៉ុកមិញ ហើយកំណត់ទិសដៅតស៊ូ " ពង្រឹងនិងពង្រីកសង្គ្រាមឈ្លបនិងពង្រីកកងទ័ព " ក្រោមការជួយឧបត្ថម្ភពីសំណាកវៀតណាមរណសិរ្ស។

ចាប់ពីពេលនោះទំនាក់ទំនងកម្ពុជានិងវៀតណាម មាននយោបាយឯកភាពសាមគ្គីគ្នា កាន់តែរឹងមាំក្នុងទិសដៅតស៊ូ ដើម្បីសិទ្ធិរបស់ជាតិខ្លួន។ កម្លាំងស្នេហាជាតិរបស់ប្រជាជនទាំងពីរកាន់តែផុលផុសខ្លាំងឡើងៗ សង្គ្រាមឈ្លបបានទទួលជោគជ័យជាបន្តបន្ទាប់ ពីបន្ទាយយោធាបារាំងនៅ ឿន-ឌៀនភូ ត្រូវបានបរាជ័យនៅឆ្នាំ១៩៥៤ ការបរាជ័យរបស់បារាំង បង្ហាញឱ្យឃើញថា បារាំងបានចាញ់សង្គ្រាមនៅឥណ្ឌូចិន ដោយបានប្រគល់ឯករាជ្យដល់ប្រទេសនីមួយៗដោយឥតលក្ខខ័ណ្ឌ។

ភាពខ្លាំងនៃទំនាក់ទំនងកម្ពុជានិងវៀតណាម មួយផ្នែកបានទទួលឥទ្ធិពលពីបដិវត្តន៍ខែតុលានៅរុស្សី បានផ្សព្វផ្សាយចូលមកក្នុងឧបទ្វីបឥណ្ឌូចិន គឺចាប់ពីពេលដែលបក្សកុម្មុយនីស្តឥណ្ឌូចិនបានកកើតឡើង ទើបសម្ព័ន្ធអន្តរជាតិនិយម រវាងប្រជាជនបដិវត្តន៍នៃប្រទេសទាំងបី បានសម្រេចឡើងប្រកបដោយមនសិការស្រឡាញ់ជាតិជាទីបំផុត។ ចាប់ពីពេលនោះមកការប្រយុទ្ធរួមគ្នានៃប្រជាជននៃប្រទេសទាំងបី បានឈានចូលទៅក្នុងសករាជថ្មីមួយ ស្ថិតនៅក្រោមការដឹកនាំនៃសេនាធិការតែមួយ។

យោងតាមការលើកឡើងរបស់បក្សកុម្មុយនីស្តឥណ្ឌូចិននេះ ទើបនៅឆ្នាំ១៩៤៩ ពួកកុម្មុយនីស្តវៀតណាមបង្កើតគណៈកម្មាធិការឃោសនាមួយ ដើម្បីបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជា។ នៅខែមីនាឆ្នាំ១៩៥០ តំណាងរណសិរ្សរំដោះជាតិនៃប្រទេសទាំងបី កម្ពុជា វៀតណាម និងឡាវ ដែលបានបង្រួបបង្រួមប្រជាជននៃប្រទេសទាំងបី ក្នុងការតស៊ូប្រឆាំងនឹងសត្រូវរួម គឺអាណានិគមនិយមបារាំង។ ដោយយោងតាមសេចក្ដីសម្រេចចិត្តនៅក្នុងឆ្នាំ១៩៥១ នៅលើទឹកដីនៃប្រទេសកម្ពុជា ពួកវៀតមិញបានធ្វើសកម្មភាពសឹកយ៉ាងសកម្ម ដើម្បីរំដោះប្រទេសកម្ពុជាពីពួកអាណានិគមនិយមបារាំង។

ខ្សោយនៃទំនាក់ទំនងកម្ពុជានិងវៀតណាម នៅត្រង់ថា បក្សកុម្មុយនីស្តឥណ្ឌូចិនកម្ពុជា មានជនជាតិវៀតណាម ជាអ្នកចាត់ចែងកិច្ចការក្នុងនិងក្រៅបក្សសព្វបែបយ៉ាង។ លោក ងៀង ថាញ់សឹងគូសបញ្ជាក់ថា " នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា មានជនជាតិវៀតណាមភាគច្រើនលើសលុប "។ រាល់ការសម្រេចរបស់បក្ស ស្ថិតនៅក្នុងកណ្ដាប់ដៃវៀតណាម។ មិនតែប៉ុណ្ណោះ ពួកកុម្មុយនីស្តវៀតណាមបង្កើតស្ថាប័នផ្សេងៗជាច្រើនទៀត ដោយលើកផ្លាកថាជួយកម្ពុជា ដូចជាការបង្កើត "កងទ័ពវៀតណាមដើម្បីជួយកម្ពុជា "ស្ថាប័ននេះមានភារកិច្ចការពារពួកកុម្មុយនីស្តវៀតណាម ក្នុងសកម្មភាពឃោសនាអប់រំ និងជ្រើសរើសសមាជិកបក្សប្រជាជនបដិវត្តន៍នៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត វៀតណាម



Scanned by CamScanner

បានត្រៀមរួចជាស្រេច នូវទីបញ្ជាការរបស់កម្លាំងយោធា និងនយោបាយវៀតមិញនៅខាងត្បូង។ វៀតណាមបានមកបោះទីតាំងរបស់ខ្លួននៅខេត្តព្រៃវែង (ក្របៅ) គឺនៅទីនោះហើយដែលពួកកុម្មុយនីស្តវៀតណាម រៀបចំចាត់តាំងបណ្តាញសម្រាប់ចាត់តាំងបក្សប្រជាជនបដិវត្តកម្ពុជា។

មេដឹកនាំបក្សកុម្មុយនីស្តខ្មែរ លោក ស៊ឺង ង៉ុកថាញ់ មិនសូវយល់ព្រឹត្តការណ៍ដែលកើតមានឡើង កំពុងកើតមាននៅក្នុងសាកលលោកពេលនោះផងទេ។ លោកមិនបានគិតផងទេថា តើក្នុងសង្គ្រាម ដែលកំពុងឆាបឆេះពេញសាកលលោកពេលនោះ នរណាច្បាំងជាមួយនរណា? នរណាចងសម្ព័ន្ធភាពជាមួយនរណាដើម្បីផលប្រយោជន៍អ្វីនោះទេ? នេះហើយ ដែលនាំឱ្យលោកមិនយល់ពីមហិច្ឆិតាវែងឆ្ងាយរបស់ជប៉ុនពេលនោះ។ យើងទទួលស្គាល់ថា លោកជាវីរជនស្នេហាជាតិមួយរូប ដែលចង់រំដោះប្រទេសកម្ពុជាឱ្យរួចផុតពីអាណានិគមបារាំង។ តែលោកទៅពឹងជប៉ុន ដើម្បីវាយបារាំងប្រថុយប្រថានបំផុត ពីព្រោះលោកពុំបានគិតថាបើ ជប៉ុនឈ្នះនៅពេលនោះ តើជប៉ុននិងប្រគល់កម្ពុជាជូនប្រជាជនកម្ពុជា ដូចគំនិតដែលលោកចង់បានដែរឬទេ? លោកមានបានគិតថា តើជប៉ុនចូលឥណ្ឌូចិនតាមរយៈនរណា? ហើយអ្នកនោះមានទំនាក់ទំនងកម្រិតណាជាមួយជប៉ុន? សំណួរទាំងអស់នេះឆ្លុះបញ្ចាំងថា លោកមិនបានត្រិះរិះពិចារណាពីទំនាក់ទំនងជប៉ុននិងថៃឡើយ? ហេតុនេះហើយពេលឈ្នះសង្គ្រាមជប៉ុន បានកាត់ទឹកដីខ្មែរនៅភូមិភាគខាងលិចឱ្យទៅប្រទេសថៃ រួមទាំងអង្គរវត្តផងដែរ នោះហើយជាហេតុនាំឱ្យជនជាតិថៃសព្វថ្ងៃនៅតែយល់ច្រឡំអង្គរវត្តជារបស់គេទាំងគឃ្លើន។

ចំណុចខ្សោយមួយទៀតអំពីខ្មែរឥស្សរៈ មាននិន្នាការងាកមករកកុម្មុយនីស្ត ជាពិសេសជនកុម្មុយនីស្តខ្មែរ បានបង្កើតភាពជូរចត់ទៅលើប្រទេសវៀតណាម ចាប់តាំងពីក្រោយសន្និសិទទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ នៅពេលនោះទើបកម្ពុជា បានដឹងថាវៀតណាមដែលជាសមភាគីតែមួយគត់របស់ខ្លួនបានក្បត់នឹងខ្លួនហើយ។ អារម្មណ៍បែបនេះកាន់តែធ្ងន់ធ្ងរឡើងៗនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ទោះបីជាវៀតណាម បានជួយខ្មែរក្រហមក្នុងការតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ ដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិក និងបានទម្លាក់សម្តេចព្រះនរោត្តមសីហនុ ចេញពីអំណាចនៅខែមីនា ឆ្នាំ១៩៧០ ក៏ដោយ ក៏ភាពតានតឹងនោះបានកើតឡើងសាជាថ្មី បន្ទាប់ពីការចរចានៅក្រុងប៉ារីសក្នុងឆ្នាំ១៩៧២-១៩៧៣ រវាងវៀតណាម និងសហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកទាមទារឱ្យពួកកុម្មុយនីស្តខ្មែរ ចូលចរចាជាមួយនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោក លន់ ណុល។ ប៉ុន្តែពួកកុម្មុយនីស្ត បានបដិសេធ ដោយជឿថាខ្លួនជិតឈានទៅសម្រេចជ័យជំនះទៅហើយ។

ចំពោះ ទំនាក់ទំនងរវាងវៀតណាមនិងស.រ.អ. វិញបានចុះហត្ថលេខាសន្ធិសញ្ញាសន្តិភាពមួយនៅឆ្នាំ១៩៧៣ ហើយសហរដ្ឋអាមេរិកបានចាប់ផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា។ ពួកកុម្មុយនីស្តចាត់ទុកថា វៀតណាមបានក្បត់នឹងខ្លួន ដែលបណ្តាលឱ្យយន្តហោះអាមេរិកទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់មកលើទឹកដីកម្ពុជា។ បន្ទាប់ពីមានកិច្ចព្រមព្រៀង នេះភ្លាមពួកកុម្មុយនីស្តខ្មែរក្រហម បានវាយប្រហារទៅលើឃ្លាំងអាវុធ មន្ទីរពេទ្យ និងជំរំកងទ័ព ព្រមទាំងបានសម្លាប់កម្មាភិបាលវៀតណាមនៅក្នុងទឹកដីនៃប្រទេសកម្ពុជា។

<u>ជំពូក៣</u> សិក្សាអំពីឥទ្ធិពលវៀតណាម មកលើកម្ពុជាក្នុងដំណាក់កាលសង្គ្រាមស៊ីវិល បើធ្វើការសិក្សាឱ្យស៊ីជម្រៅទៅ មូលហេតុនៃជម្លោះ រវាងកម្ពុជាប្រជាធិបតេយ្យ និង សាធារណរដ្ឋសង្គមនិយម វៀតណាម បណ្តាលពីអតីតមេដឹកនាំបក្សកុម្មុយនីស្តទាំងពីរកម្ពុជានិងវៀតណាម ជាអ្នកបញ្ឆេះសង្គ្រាម បង្ហូរឈាមនេះឡើង។ សង្គ្រាមនេះបណ្តាលមកកត្តាធំបីគឺ៖ កត្តាទីមួយ: បណ្តាលមកពី



Scanned by CamScanner

